អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គភាពគាំពារជនរងគ្រោះ
Victims Support Section
Section d'appui aux victimes

ថ្ងៃទី៣០ ខែមិថុនា ២០១៦

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលវេទិកាស្តីពីការវិវឌ្ឍន៍ថ្មីៗ
# នៃនីតិវិធី អ.វ.ត.ក និងសំណងក្នុងសំណុំរឿង ០០២/០២

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានរៀបចំវេទិកាប្រកបដោយជោគជ័យដោយមានការអញ្ជើញចូលរួមពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំមុខ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង មន្ត្រីមកពី អ.វ.ត.ក និងស្ថានទូតនៃសាធារណរដ្ឋសហព័ន្ធអាឡឺម៉ង់ ព្រមទាំងតំណាងអង្គការជាតិ និងអន្តរជាតិជាច្រើនរូបទៀត។

បន្ទាប់ពីសុន្ទរកថាបើកដោយ ឯកឧត្តម **ក្រាញ់ តូនី** ប្រធានការិយាល័យរដ្ឋបាលស្តីទី នៃ អ.វ.ត.ក និងលោកស្រីបណ្ឌិត Ludgera Klemp អគ្គកុងស៊ុល និងជាប្រមុខសហប្រតិបត្តិការស្ថានទូតនៃសាធារណរដ្ឋសហព័ន្ធអាឡឺម៉ង់ប្រចាំប្រទេសកម្ពុជារួចមក វេទិកាបានដំណើរការបន្តដោយការផ្តល់ព័ត៌មានស្តីពីបច្ចុប្បន្នភាពរបស់ អ.វ.ត.ក។ បទបង្ហាញបន្ទាប់ទៀតស្តីពីសំណងក្នុងសំណុំរឿង ០០២/០១ និង០០២/០២ ធ្វើឡើងដោយអង្គភាពគាំពារជនរងគ្រោះ និងអង្គភាពសហមេធាវីនាំមុខ។ តំណាងមកពីមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ (LDC) អង្គការមនុស្សចាស់កម្ពុជា (HelpAge Cambodia) និងមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា (Bophana) ក៏ បានធ្វើបទបង្ហាញស្តីពីគម្រោងសំណងដែលបានស្នើឡើងក្នុងសំណុំរឿង ០០២/០២ ផងដែរ ដោយមានការចូលរួមយ៉ាងសកម្ម និងប្រកបដោយអត្ថន័យពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគាត់។

ឯកឧត្តម **ក្រាញ់ តូនី** បានមានប្រសាសន៍ថា គម្រោងសំណង ១១ ដែលបានដាក់ស្នើក្នុងសុំណុំរឿង ០០២/០១ ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ។ ភាគច្រើននៃគម្រោងទាំងនោះ ទទួលបានជំនួយឧបត្ថម្ភ និងអនុវត្តប្រកបដោយជោគជ័យនៅទូទាំងប្រទេស។ ឯកឧត្តមសង្ឃឹមថា សំណងក្នុងសំណុំរឿង ០០២/០២ នឹងអាចធ្វើដំណើរឆ្ពោះទៅមុខជាថ្មីម្តងទៀតយ៉ាងរលូនសម្រាប់ជាប្រយោជន៍ដល់ជនរងគ្រោះ។ ឯកឧត្តមបានបន្ថែមទៀតថា រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងគាំទ្រដល់ដំណើរការរបស់ អ.វ.ត.ក និងការអនុវត្តគម្រោងសំណងក្នុងក្របខ័ណ្ឌច្បាប់របស់តុលាការ។

លោកស្រីបណ្ឌិត Klemp បានថ្លែងលើកទឹកចិត្តដល់អ្នកចូលរួមទាំងអស់ ឲ្យមានការពិភាក្សាគ្នាផុសផុលស្តីពីដំណើរការវិវឌ្ឍន៍នៃនិតិវិធីរបស់ អ.វ.ត.ក និងសំណង។ លោកស្រីបណ្ឌិតបន្តថា ប្រទេសអាឡឺម៉ង់រួមជាមួយនឹងបណ្តាប្រទេសដទៃទៀត បាននិងកំពុង គាំទ្រដល់សកម្មភាពរបស់ អ.វ.ត.ក។ ប្រទេសអាឡឺម៉ង់បានគាំទ្រដល់គម្រោងនៃវិធានការនានាមិនពាក់ព័ន្ធបច្ចេកទេសតុលាការ និងគម្រោងសំណងជាច្រើនរួចមកហើយក្នុងសំណុំរឿង ០០២/០១ ក្នុងនោះរួមមាន៖ គម្រោងកសាងមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍ ក្រាំង តាចាន់ ស្ថិតនៅខេត្ត តាកែវ ស្តូបរំលឹកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យនៅសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ការព្យាបាលតាមបែបផ្តល់សក្ខីកម្ម និងក្រុមជួយខ្លួនឯង និងការតាំងពិព័រណ៍ចល័តស្តីពីការជម្លៀសដោយបង្ខំនិងការសម្លាប់នៅទួលពោធិ៍ជ្រៃ។ លោកស្រីបណ្ឌិត Klemp បានបន្តទៀតថា បន្ថែមលើជំនួយមុនៗកន្លងមក ក្នុងពេលថ្មីៗនេះ ប្រទេសអាឡឺម៉ង់ រួមជាមួយប្រទេសស្វីស និង អង្គការសហប្រជាជាតិដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women) បានសម្រេចផ្តល់ជំនួយឧបត្ថម្ភដល់គម្រោង “ផ្កាស្លាក្រោមអង្គការ” ដែលជាគម្រោងមួយបានដាក់ស្នើក្នុងសំណុំរឿង ០០២/០២ និង អនុវត្តដោយ អង្គការក្រៅរដ្ឋាភិបាលមួយក្រុម។

ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចូលរួមវេទិកាមានការពេញចិត្តជាមួយការពិភាក្សា និងបទបង្ហាញស្តីពី គម្រោងសំណងដែលបានស្នើឡើង។ ពួកគាត់យល់ថា តាមក្របខ័ណ្ឌច្បាប់ របស់ អ.វ.ត.ក សំណងមានលក្ខណៈជា “ផ្លូវចិត្ត និងសមូហភាព” តែប៉ុណ្ណោះ ហើយពួកគាត់បានស្នើសុំឲ្យមានការអនុវត្តគម្រោងសំណងប្រកបដោយប្រសិទ្ធភាព។

វេទិកាដើមបណ្តឹងរដ្ឋប្បវេណី គឺជាកន្លែងមានសុវត្ថិភាពមួយដែលដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគាត់អាចជួបប្រជុំពិភាក្សាគ្នាស្តីពី ដំណើរការវិវឌ្ឍន៍នៃនីតិវិធី អ.វ.ត.ក និងសំណង សម្រាប់ជាប្រយោជន៍ដល់ពួកគាត់ក៏ដូចជាមនុស្សជំនាន់ក្រោយៗទៀត។

ចាប់តាំងពីដំណើរការដំបូងនៃនិតិវិធីសំណុំរឿងលេខ ០០២/០២ មក អង្គភាពគាំពារជនរងគ្រោះបានរៀបចំវេទិកាចំនួន១៣ លើក ហើយមានដើមបណ្តឹងរដ្ឋប្បវេណីប្រមាណជា ១,៤៥៦ នាក់ បានមកចូលរួមក្នុងកិច្ចពិភាក្សា និងបទបង្ហាញផ្សេងៗ។

**ព័ត៌មានបន្ថែម សូមទាក់ទង**

លោក ហង្ស វណ្ណៈ
ប្រធានអង្គភាពគាំពារជនរងគ្រោះ
សារអេឡិចត្រូនិច: hang.vannak@eccc.gov.kh